**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**ខុទ្ទកាល័យរដ្ឋមន្ត្រី**
លេខ:...០៧៦/២០... ក.ប/ខ.ល.

# សេចក្តីណែនាំ
# ស្តីពី
# គំរូនៃការតាក់តែងលិខិតបទដ្ឋានគតិយុត្ត និងលិខិតរដ្ឋបាល សម្រាប់ប្រើប្រាស់ផ្ទៃក្នុងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ដើម្បីធានានូវសង្គតិភាពក្នុងការតាក់តែងលិខិតបទដ្ឋានគតិយុត្ត និងលិខិតរដ្ឋបាលគ្រប់ប្រភេទតាមបណ្តាអង្គភាពទាំងអស់ក្រោមឱវាទ ខុទ្ទកាល័យសូមធ្វើការណែនាំដូចខាងក្រោម៖

**ក-លិខិតបទដ្ឋានគតិយុត្ត** (**ប្រកាស សេចក្តីសម្រេច សារាចរ**)

១. **ប្រកាស** ត្រូវបានបែងចែកជា ២ប្រភេទ ដូចខាងក្រោម៖

- ប្រកាសមានលក្ខណៈជាបទប្បញ្ញត្តិទូទៅ ជាការណែនាំការអនុវត្ត ឬបញ្ជាក់បន្ថែមខ្លឹមសាររបស់ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬការអនុវត្តកិច្ចការដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន ឬការដាក់ចេញវិធានការចាំបាច់ណាមួយ និងផ្សេងៗ ដូចមានគំរូក្នុង**ឧបសម្ព័ន្ធ១ ឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣** និង**ឧបសម្ព័ន្ធ៤**។
- ប្រកាសមានលក្ខណៈឯកត្តភូត ជាប្រកាសដែលទាក់ទង ឬសំដៅចំឈ្មោះបុគ្គល ដូចជា៖ ការជ្រើសរើសក្របខណ្ឌ ការធ្វើកម្មសិក្សា ការតាំងស៊ប់ ការតែងតាំង ការប្រគល់ភារកិច្ច ការផ្លាស់ប្តូរមន្ត្រីរាជការ ការដំឡើងឋានន្តរសក្តិ ថ្នាក់ និងផ្សេងៗ ដូចមានគំរូក្នុង**ឧបសម្ព័ន្ធ៥ ឧបសម្ព័ន្ធ៦ ឧបសម្ព័ន្ធ៧** និង**ឧបសម្ព័ន្ធ៨**។

២. **សេចក្តីសម្រេច** ត្រូវអនុលោមតាម **ឧបសម្ព័ន្ធ៩** និង**ឧបសម្ព័ន្ធ១០**

៣. **សារាចរ** ត្រូវអនុលោមតាម **ឧបសម្ព័ន្ធ១១**។

**ខ-លិខិតរដ្ឋបាល**

លិខិតរដ្ឋបាល ជាលិខិតស្នាមទាំងឡាយដែលត្រូវបានតាក់តែងឡើងសម្រាប់ទំនាក់ទំនងក្នុងក្របខណ្ឌជាផ្លូវការជាមួយអន្តរក្រសួង ស្ថាប័ន និងលិខិតរដ្ឋបាលសម្រាប់ប្រើប្រាស់ជាលក្ខណៈផ្ទៃក្នុង។

១. លិខិតរដ្ឋបាលផ្ញើជូន ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភា ត្រូវអនុលោមតាម **ឧបសម្ព័ន្ធ១២** និង **ឧបសម្ព័ន្ធ១៣**។

២. លិខិតរដ្ឋបាលផ្ញើជូន សម្តេចតេជោនាយករដ្ឋមន្ត្រី ត្រូវអនុលោមតាម **ឧបសម្ព័ន្ធ១៤**។


អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

៣. លិខិតរដ្ឋបាលផ្ញើជូន សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុលោមតាម **ឧបសម្ព័ន្ធ១៥**។

៤. លិខិតរដ្ឋបាលផ្ញើជូន ឧបនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រី ត្រូវអនុលោមតាម **ឧបសម្ព័ន្ធ១៦** និង **ឧបសម្ព័ន្ធ១៧**។

៥. លិខិតរដ្ឋបាលផ្ញើជូន រដ្ឋមន្ត្រីជាប្រធានស្ថាប័ន និងរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ត្រូវអនុលោមតាម **ឧបសម្ព័ន្ធ១៨** និង**ឧបសម្ព័ន្ធ១៩**។

៦. លិខិតរដ្ឋបាលផ្ញើជូន ប្រធានក្រុមប្រឹក្សា/អភិបាលនៃគណៈអភិបាល រាជធានី ខេត្ត ត្រូវអនុលោមតាម **ឧបសម្ព័ន្ធ២០**។

៧. លិខិតរដ្ឋបាល ក្នុងនាមថ្នាក់ដឹកនាំក្រសួងផ្ញើជូនអង្គភាពក្រោមឱវាទក្រសួង ត្រូវអនុលោមតាម **ឧបសម្ព័ន្ធ២១**។

៨. លិខិតរដ្ឋបាល ក្នុងនាមអង្គភាពក្រោមឱវាទក្រសួងផ្ញើជូនថ្នាក់ដឹកនាំក្រសួង ត្រូវអនុលោមតាម **ឧបសម្ព័ន្ធ២២**។

៩. លិខិតរដ្ឋបាល ក្នុងនាមអង្គភាពផ្ញើជូន អង្គភាព ត្រូវអនុលោមតាម **ឧបសម្ព័ន្ធ២៣**។

១០. លិខិតរដ្ឋបាល "**លិខិតអញ្ជើញ**" សម្រាប់អញ្ជើញថ្នាក់ដឹកនាំក្រសួង ឬអង្គភាពក្រោមឱវាទចូលរួមក្នុងកម្មវិធី ឬព្រឹត្តិការណ៍ដែលរៀបចំដោយក្រសួង ត្រូវអនុលោមតាម **ឧបសម្ព័ន្ធ២៤**។

១១. លិខិតរដ្ឋបាល "**របាយការណ៍**" សម្រាប់រាយការណ៍ពីលទ្ធផលការងារ ឬស្នើសុំគោលការណ៍ផ្សេងៗ ត្រូវអនុលោមតាម **ឧបសម្ព័ន្ធ២៥** និង**ឧបសម្ព័ន្ធ២៦**។

### គ-គោលការណ៍រួម

ការតាក់តែងលិខិតបទដ្ឋានគតិយុត្ត និងលិខិតរដ្ឋបាលត្រូវកំណត់ប្រភេទក្រដាសកិច្ចការ (Page Setup) ប្រភេទអក្សរ (Font Style) ទំហំអក្សរ (Font Size) ដូចខាងក្រោម៖

**១. ការប្រើប្រាស់ក្នុងកម្មវិធី Microsoft Office Word**

- ប្រភេទក្រដាសកិច្ចការ **A4**
- រឹមផ្នែកខាងលើ (Top Margin) កំណត់យក **១.៥សង់ទីម៉ែត្រ**
- រឹមផ្នែកខាងក្រោម (Bottom Margin) កំណត់យក **១.៥សង់ទីម៉ែត្រ**
- រឹមផ្នែកខាងឆ្វេង (Left Margin) កំណត់យក **២សង់ទីម៉ែត្រ**
- រឹមផ្នែកខាងស្តាំ (Right Margin) កំណត់យក **១.៥សង់ទីម៉ែត្រ**
- សម្រាប់មូលបទរបស់លិខិតបទដ្ឋានគតិយុត្ត ត្រូវប្រើប្រាស់ប្រភេទអក្សរ **Khmer OS Battambang** និង**ទំហំអក្សរ ១១**
- ខ្លឹមសារលិខិត ត្រូវប្រើប្រាស់ប្រភេទអក្សរ **Khmer OS Muol Light** និង **Khmer OS Battambang** និង**ទំហំអក្សរ ១២**។ ចំពោះចម្លងជូន (លិខិតរដ្ឋបាល) ឬកន្លែងទទួល (លិខិតបទដ្ឋានគតិយុត្ត) ត្រូវប្រើប្រាស់ប្រភេទអក្សរ **Khmer OS Muol Light** និង **Khmer OS Battambang** និង**ទំហំអក្សរ ៩**
- ពេលចូលបន្ទាត់នីមួយៗ **ត្រូវប្រើ Key Tab** មិនត្រូវប្រើ Key Spacebar នោះទេ។

**២. ការប្រើប្រាស់ក្នុងកម្មវិធី Microsoft Office Excel**

- ប្រភេទក្រដាសកិច្ចការ **A4**
- រឹមផ្នែកខាងលើ (Top Margin) កំណត់យក **0.២សង់ទីម៉ែត្រ**
- រឹមផ្នែកខាងក្រោម (Bottom Margin) កំណត់យក **0.២សង់ទីម៉ែត្រ** (ចំពោះឯកសារ ១ទំព័រ) និង **0.៥សង់ទីម៉ែត្រ** (ចំពោះឯកសារចាប់ពី ២ទំព័រឡើង)
- រឹមផ្នែកខាងឆ្វេង (Left Margin) កំណត់យក **0.៣សង់ទីម៉ែត្រ**
- រឹមផ្នែកខាងស្តាំ (Right Margin) កំណត់យក **0.២សង់ទីម៉ែត្រ**
- អញ្ញត្តិច្រើន ដាក់ជាជួរដេក (Row) និងអញ្ញត្តិតិច ដាក់ជាជួរឈរ (Column)។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាថ្នាក់ដឹកនាំ និងប្រធានអង្គភាពក្រោមឱវាទក្រសួង ទាំងអស់ជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាពប្រកប ដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០២០

**រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ**

**ហេង សួរ**

**ចម្លងជូន:**

- ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
- ឯកសារ កាលប្បវត្តិ

ក្បាលលិខិត Letter Head

**ប្រកាស**

**ស្តីពី**

..............................................................

Khmer OS Muol Light ទំហំ ១២

(Tacteing ទំហំ ២២)

០.២៥ ស.ម

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

Spacing: after 0.8 pts
Line Spacing: Single

១.២៥ ស.ម

Khmer OS Battambang ទំហំ ១១

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃ៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះអនុក្រឹត្យលេខ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ..............................................................
- ..............................................................
- ..............................................................

Khmer OS Muol Light ទំហំ ១២

**សម្រេច**

**ប្រការ១ ..**

..............................................................

..............................................................។

**ប្រការ២ ..**

..............................................................៖

Khmer OS Battambang ទំហំ ១២

១.២៥ ស.ម

- ..............................................................
- ..............................................................
- ..............................................................។

**ប្រការ... .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ... .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន ......................................................................................................................................................................................................................................... ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

Khmer OS Battambang ទំហំ ១២ ← ថ្ងៃ......................ខែ............ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..........ខែ...........ឆ្នាំ២០២០

Khmer OS Muol Light ទំហំ ១២ ← **រដ្ឋមន្ត្រី**

**កន្លែងទទួល:** Khmer OS Muol Light ទំហំ ៩

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ..............................
- ..............................
- ..............................
- ឯកសារ កាលប្បវត្តិ

} Khmer OS Battambang ទំហំ ៩

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ឧបសម្ព័ន្ធ១**
ប្រកាសមានលក្ខណៈជាបទប្បញ្ញត្តិទូទៅ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ :..........................................ក.ប**

# ប្រកាស
# ស្តីពី

..............................................................

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញ *(ព្រះរាជក្រម ឬព្រះរាជក្រឹត្យ ដែលពាក់ព័ន្ធនឹងខ្លឹមសារប្រកាស ប្រសិនបើមាន)*
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញ *(អនុក្រឹត្យ សេចក្តីសម្រេច សារាចរ របស់រាជរដ្ឋាភិបាល ឬប្រកាស ដែលពាក់ព័ន្ធនឹងខ្លឹមសារប្រកាស ប្រសិនបើមាន)*
- *(យោងឯកសារពាក់ព័ន្ធទៅនឹងរឿង ឬអង្គភាពសាមី ប្រសិនបើមាន)*
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## សម្រេច

**ប្រការ១ ..**

.......................................................................................................................... ។

**ប្រការ២ ..**

.......................................................................................................................... ។

**ប្រការ.... ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

(ប្រការនេះមិនត្រូវចែងទេ ក្នុងករណីជាក់ស្តែងដែលមិនតម្រូវឱ្យនិរាករណ៍លិខិតបទដ្ឋានគតិយុត្តមុនៗដែលពាក់ព័ន្ធ)។

**ប្រការ**.... ..

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន .................... (ប្រធានអង្គភាពដែលទទួលបន្ទុករៀបចំ ឬអនុវត្ត) និងប្រធានអង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.......................ខែ...........ឆ្នាំ...............ព.ស.២៥....

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...........ខែ.............ឆ្នាំ២០...

**រដ្ឋមន្ត្រី**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យ**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី**
- ក្រសួង-ស្ថាប័ន *(ដែលពាក់ព័ន្ធប៉ុណ្ណោះ ប្រសិនបើមាន)*
- រដ្ឋបាលរាជធានី-ខេត្ត(...) *(ដែលពាក់ព័ន្ធប៉ុណ្ណោះ ប្រសិនបើមាន)*
- ដូចប្រការ(...) *(ប្រការចុងក្រោយនៃប្រកាស)*
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ឧបសម្ព័ន្ធ២**
ប្រកាសមានលក្ខណៈជាបទប្បញ្ញត្តិទូទៅ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ :.....................................ក.ប**

# ប្រកាស
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅរបស់.............................................

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញ *(ព្រះរាជក្រម ឬព្រះរាជក្រឹត្យ ដែលពាក់ព័ន្ធនឹងខ្លឹមសារប្រកាស ប្រសិនបើមាន)*
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញ *(អនុក្រឹត្យ សេចក្តីសម្រេច សារាចរ របស់រាជរដ្ឋាភិបាល ឬប្រកាស ដែលពាក់ព័ន្ធនឹងខ្លឹមសារប្រកាស ប្រសិនបើមាន)*
- *(យោងឯកសារពាក់ព័ន្ធទៅនឹងរឿង ឬអង្គភាពសាមី ប្រសិនបើមាន)*
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ..**

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ...... និងអង្គភាពជំនាញនានា ចំណុះឱ្យ(...........)សំដៅពង្រឹងប្រសិទ្ធភាពការងារនៅតាមអង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ.... .-**

ប្រកាសនេះ មានគោលបំណងដូចខាងក្រោម៖

- ................................................................................................................................
- ..............................................................................................................................។

## ជំពូកទី២
## បេសកកម្ម និងរចនាសម្ព័ន្ធ

**ប្រការ.... .-**

.......................................................................................................................................។

## ជំពូកទី៣
## ភារកិច្ចរបស់ការិយាល័យ និងអង្គភាព

**ប្រការ.... .-**

.......................................................................................................................................។

## ជំពូកទី.....

..........................................................

**ប្រការ.... .-**

.......................................................................................................................................។

## ជំពូកទី.....
## អវសានប្បញ្ញត្តិ

**ប្រការ.... .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

(ប្រការនេះមិនត្រូវចែងទេ ក្នុងករណីជាក់ស្តែងដែលមិនតម្រូវឱ្យនិរាករណ៍លិខិតបទដ្ឋានគតិយុត្តមុនៗដែលពាក់ព័ន្ធ)។

**ប្រការ.... .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន .................... (ប្រធានអង្គភាពដែលទទួលបន្ទុករៀបចំ ឬអនុវត្ត) និងប្រធានអង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.......................ខែ..........ឆ្នាំ..............ព.ស.២៥....

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...........ខែ............ឆ្នាំ២០...

**រដ្ឋមន្ត្រី**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យ**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី**
- ក្រសួង-ស្ថាប័ន *(ដែលពាក់ព័ន្ធប៉ុណ្ណោះ ប្រសិនបើមាន)*
- រដ្ឋបាលរាជធានី-ខេត្ត(...) *(ដែលពាក់ព័ន្ធប៉ុណ្ណោះ ប្រសិនបើមាន)*
- ដូចប្រការ(...) *(ប្រការចុងក្រោយនៃប្រកាស)*
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ឧបសម្ព័ន្ធ៣**
ប្រកាសមានលក្ខណៈជាបទប្បញ្ញត្តិទូទៅ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :......................................ក.ប

# ប្រកាស
## ស្តីពី
## ការបង្កើតឬកែសម្រួលសមាសភាពក្រុមការងាររបស់..............................................

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញ *(ព្រះរាជក្រម ឬព្រះរាជក្រឹត្យ ដែលពាក់ព័ន្ធនឹងខ្លឹមសារប្រកាស ប្រសិនបើមាន)*
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញ *(អនុក្រឹត្យ សេចក្តីសម្រេច សារាចរ របស់រាជរដ្ឋាភិបាល ឬប្រកាស ដែលពាក់ព័ន្ធនឹងខ្លឹមសារប្រកាស ប្រសិនបើមាន)*
- *(យោងឯកសារពាក់ព័ន្ធទៅនឹងរឿង ឬអង្គភាពសាមី ប្រសិនបើមាន)*
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## សម្រេច

**ប្រការ១ ..**

ត្រូវបានបង្កើត/កែសម្រួលសមាសភាពរបស់ក្រុមការងាររបស់.......................ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| - ឯកឧត្តម/លោកជំទាវ | ...... | (មុខតំណែង) | ប្រធាន |
| - ឯកឧត្តម/លោកជំទាវ | ...... | (មុខតំណែង) | អនុប្រធាន |
| - ឯកឧត្តម/លោកជំទាវ | ...... | (មុខតំណែង) | សមាជិក/សមាជិកា |

- លោក/លោកស្រី ...... (មុខតំណែង) សមាជិក/សមាជិកា
- លោក/លោកស្រី ...... (មុខតំណែង) សមាជិក/សមាជិកា
- លោក/លោកស្រី ...... (មុខតំណែង) សមាជិក/សមាជិកា

**ប្រការ២ .-**

ក្រុមការងារនេះមានភារកិច្ចសំខាន់ៗដូចជា៖

- ...........................................................................................................
- ...........................................................................................................
- ...........................................................................................................
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាព..............ជូនប្រធានស្ថាប័នជាប្រចាំ
- អនុវត្តភារកិច្ចផ្សេងៗតាមការចាត់តាំងរបស់ប្រធានស្ថាប័ន។

**ប្រការ៣ .-**

ប្រធានក្រុមការងារ អាចអញ្ជើញអង្គភាពពាក់ព័ន្ធចូលរួមប្រជុំតាមការចាំបាច់។

សមាជិកនៃក្រុមការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ។

**ប្រការ.... .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

(ប្រការនេះមិនត្រូវចែងទេ ក្នុងករណីជាក់ស្តែងដែលមិនតម្រូវឱ្យនិរាករណ៍លិខិតបទដ្ឋានគតិយុត្តមុនៗដែលពាក់ព័ន្ធ)។

**ប្រការ.... .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន ................... (ប្រធានអង្គភាពដែលទទួលបន្ទុករៀបចំ ឬអនុវត្ត) ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.......................ខែ...........ឆ្នាំ...............ព.ស.២៥....

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...........ខែ.............ឆ្នាំ២០...

**រដ្ឋមន្ត្រី**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័ន *(ដែលពាក់ព័ន្ធ ប្រសិនបើមាន)*
- ដូចប្រការ(...) *(ប្រការចុងក្រោយនៃប្រកាស)*
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ :.......................................ក.ប**

**ឧបសម្ព័ន្ធ៤**
ប្រកាសអន្តរក្រសួងមានលក្ខណៈជាបទប្បញ្ញត្តិទូទៅ

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតក្រុម......... អន្តរក្រសួងក្នុងវិស័យ............................

**រដ្ឋមន្ត្រី** **រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** .............................................................

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/........./.......... ចុះថ្ងៃទី......... ខែ........ ឆ្នាំ......... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង...........................................................
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ............ អនក្រ/បក ចុះថ្ងៃទី...... ខែ....... ឆ្នាំ........... ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង...............................................
- *(យោងឯកសារពាក់ព័ន្ធទៅនឹងរឿង ឬអង្គភាពសាមី ប្រសិនបើមាន)*
- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់ក្រសួង...........( ឈ្មោះក្រសួង ស្ថាប័នរៀបចំប្រកាសអន្តរក្រសួងនេះ) ឬ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង..... (ឈ្មោះក្រសួង ស្ថាប័នសាមី) ។

## សម្រេច

**ប្រការ១ ..**

........................................................................................................................................ ។

**ប្រការ២ ..**

..................................................................................................................................................................។

**ប្រការ.... ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

(ប្រការនេះមិនត្រូវចែងទេ ក្នុងករណីជាក់ស្តែងដែលមិនតម្រូវឱ្យនិរាករណ៍លិខិតបទដ្ឋានគតិយុត្តមុនៗដែលពាក់ព័ន្ធ)។

**ប្រការ.... ..**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន................ អគ្គាធិការ(ឬប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ អធិការ.....) ប្រធានមន្ទីរ...... រាជធានី ខេត្ត នៃក្រសួង..... និងក្រសួង..... ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ......................ខែ...........ឆ្នាំ...............ព.ស.២៥....

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ២០...

**រដ្ឋមន្ត្រី** **រដ្ឋមន្ត្រី**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ............................................................

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យ**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី**
- ក្រសួង-ស្ថាប័ន *(ដែលពាក់ព័ន្ធប៉ុណ្ណោះ ប្រសិនបើមាន)*
- រដ្ឋបាលរាជធានី-ខេត្ត(...) *(ដែលពាក់ព័ន្ធប៉ុណ្ណោះ ប្រសិនបើមាន)*
- ដូចប្រការ(...) *(ប្រការចុងក្រោយនៃប្រកាស)*
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ .........................................ក.ប

**ឧបសម្ព័ន្ធ៥**
ប្រកាសមានលក្ខណៈជាបទប្បញ្ញត្តិឯកត្តភូត

# ប្រកាស
# ស្តីពី
# ការតែងតាំង ប្រគល់ភារកិច្ច និងកែសម្រួលភារកិច្ចមន្ត្រីរាជការ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញ *(ព្រះរាជក្រម ឬព្រះរាជក្រឹត្យ ដែលពាក់ព័ន្ធនឹងខ្លឹមសារប្រកាស ប្រសិនបើមាន)*
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញសារាចរណែនាំលេខ១០ សរ.ណន ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីនីតិវិធីនៃការតែងតាំងមន្ត្រីរាជការស៊ីវិលរបស់រាជរដ្ឋាភិបាលកម្ពុជា
- *(យោងឯកសារពាក់ព័ន្ធទៅនឹងរឿង ឬអង្គភាពសាមី ប្រសិនបើមាន)*
- យោងលិខិតលេខ.................... មស.គត ចុះថ្ងៃទី..... ខែ..... ឆ្នាំ...... របស់ក្រសួងមុខងារសាធារណៈ

## សម្រេច

**ប្រការ១ ..**

តែងតាំងមន្ត្រីរាជការចំនួន .......រូប តាមបណ្តាអង្គភាពដូចខាងក្រោម៖

១.លោក .................. ក្របខណ្ឌ......... ជា........... នៃ(ឈ្មោះអង្គភាព)

២.លោកស្រី .................. ក្របខណ្ឌ......... ជា........... នៃ(ឈ្មោះអង្គភាព)

**ប្រការ២ .-**

ប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន .......រូប តាមបណ្តាអង្គភាពដូចខាងក្រោម៖

១.លោក .................. ក្របខណ្ឌ........ ឱ្យបំពេញមុខងារជា...........នៃ(ឈ្មោះអង្គភាព)

២.លោកស្រី .................. ក្របខណ្ឌ........ ឱ្យបំពេញមុខងារជា...........នៃ(ឈ្មោះអង្គភាព)

**ប្រការ៣ .-**

កែសម្រួលភារកិច្ចមន្ត្រីរាជការចំនួន .......រូប តាមបណ្តាអង្គភាពដូចខាងក្រោម៖

១.លោក .................. ក្របខណ្ឌ........ ពី.........................................នៃ(អង្គភាពដើម)
ទៅជា....... នៃ(អង្គភាពថ្មី)

២.លោកស្រី .................. ក្របខណ្ឌ........ ពី.........................................នៃ(អង្គភាពដើម)
ទៅជា....... នៃ(អង្គភាពថ្មី)

**ប្រការ៤ .-**

មន្ត្រីរាជការដែលចាត់ឱ្យបំពេញមុខងារ ដូចមានចែងក្នុងប្រការ២ មានសិទ្ធិទទួលប្រាក់បំណាច់ទាំងឡាយណាដែលមុខតំណែងនោះទទួលបាន ហើយត្រូវបន្តឡើងថ្នាក់ក្នុងក្របខណ្ឌ និងឋានន្តរស័ក្តិរបស់ខ្លួនដែលមានមុខការចាត់ឱ្យបំពេញមុខងារនោះ។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន ............................ ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ប្រការ២ និងប្រការ៣ មានភារកិច្ចអនុវត្តតាមប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.......................ខែ...........ឆ្នាំ...............ព.ស.២៥....

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...........ខែ.............ឆ្នាំ២០...

**រដ្ឋមន្ត្រី**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ(...) *(ប្រការចុងក្រោយនៃប្រកាស)*
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

| |
|---|
| **ឧបសម្ព័ន្ធ៦** |
| ប្រកាសមានលក្ខណៈជាបទប្បញ្ញត្តិឯកត្តភូត |

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** :.......................................**ក.ប**

# ប្រកាស
# ស្តីពី
# ការលុបឈ្មោះមន្ត្រីរាជការដោយស្ម័គ្រចិត្តឬបោះបង់ឬមរណភាព

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.តត ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស *(ចំពោះមន្ត្រីស្ថិតក្នុងភាពទំនេរគ្មានបៀវត្សហើយសុំលាឈប់ដោយស្ម័គ្រចិត្តឬបោះបង់)*
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- *(យោងឯកសារពាក់ព័ន្ធទៅនឹងរឿង ឬអង្គភាពសាមី ប្រសិនបើមាន)*

## សម្រេច

**ប្រការ១ .-**

លុបឈ្មោះលោកឬលោកស្រី........................... មន្ត្រីបម្រើការងារនៅអង្គភាព............................. ចេញពីក្របខណ្ឌក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយស្ម័គ្រចិត្តឬបោះបង់ឬមរណភាពដោយគិតចាប់ពីថ្ងៃទី........ ខែ.......... ឆ្នាំ...........។

**ប្រការ២ .-**

មន្ត្រីរាជការដែលមានឈ្មោះក្នុងប្រការ១ ទទួលប្រាក់ឧបត្ថម្ភតែម្តងគត់ ដោយអនុលោមតាមអនុក្រឹត្យលេខ០៥ អនក្រ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩២ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។ *(ចំពោះលុបឈ្មោះដោយស្ម័គ្រចិត្ត ឬមរណភាព)*

មន្ត្រីរាជការដែលមានឈ្មោះក្នុងប្រការ១ មិនទទួលបានប្រាក់ឧបត្ថម្ភទេ ដោយអនុលោមតាមអនុក្រឹត្យលេខ០៥ អនក្រ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩២ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។ *(ចំពោះលុបឈ្មោះដោយបោះបង់)*

**ប្រការ៣ ._**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន ............................ ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ប្រធានអង្គភាពពាក់ព័ន្ធ និង *(សាមីខ្លួនឬគ្រួសារសព)* ដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ......................ខែ..........ឆ្នាំ..............ព.ស.២៥....

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ២០...

**រដ្ឋមន្ត្រី**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- រដ្ឋបាលរាជធានី ខេត្ត *(ចំពោះមន្ត្រីបម្រើការងារនៅថ្នាក់រាជធានី ខេត្ត)*
- ដូចប្រការ៣
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ឧបសម្ព័ន្ធ៧**

ប្រកាសមានលក្ខណៈជាបទប្បញ្ញត្តិឯកត្តភូត

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :.........................................ក.ប**

# ប្រកាស
# ស្តីពី
# ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០២ ស្តីពីការកែសម្រួលអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធបៀវត្សថ្មី
- បានឃើញអនុក្រឹត្យ២០១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការកែប្រែប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់ជូនមន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញសារាចរណែនាំលេខ០០៦ ស.អ.យ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញសារាចរណែនាំលេខ ០៥ ស.រ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលនីតិវិធីនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**ប្រការ១ ..**

ដាក់លោកឬលោកស្រី.......................... ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ កើតថ្ងៃទី.......ខែ...... ឆ្នាំ......... នៅឃុំ........ ស្រុក........ ខេត្ត........ ឱ្យចូលនិវត្តន៍ចាប់ពីថ្ងៃទី.......ខែ...... ឆ្នាំ.........។

- រយៈពេលបំពេញការងារចំនួន........ឆ្នាំ ក្នុងនោះរួមមាន៖
- ចាប់ពីថ្ងៃទី ១ មករា ១៩៩៤ ដល់ ៣ សីហា ២០០៤ ចំនួន ០៩ ឆ្នាំ ០៨ខែ ០២ថ្ងៃ ជាមន្ត្រី
- ចាប់ពីថ្ងៃទី ៤ សីហា ២០០៤ដល់ ... ........ ២០២០ ចំនួន ..... ឆ្នាំ ......ខែ ......ថ្ងៃ ជា.............
- មុខតំណែងមុនពេលចូលនិវត្តន៍៖ ជា......................... នៃ(អង្គភាព).......................................
- ស្ថាប័នធ្វើការមុនពេលចូលនិវត្តន៍៖ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- កាំប្រាក់បៀវត្សមុនពេលចូលនិវត្តន៍៖ ខ.១.៥ = ៩៥២ ៣៨០៛
- អាសយដ្ឋានក្រោយពេលចូលនិវត្តន៍៖ សង្កាត់......... ក្រុង........ រាជធានី ខេត្ត ................

**ប្រការ២ ..**

លោកឬលោកស្រី......................... ត្រូវបានលុបឈ្មោះចេញពីក្របខណ្ឌ និងផ្ដាច់ប្រាក់បៀវត្សសរុបប្រចាំខែចេញពីតារាងបៀវត្សនៃ(អង្គភាព).................. ដោយគិតចាប់ពីថ្ងៃទី.......ខែ...... ឆ្នាំ.........។

**ប្រការ៣ ..**

លោកឬលោកស្រី......................... ត្រូវបានទទួល៖

| | | |
|---|---|---|
| - ប្រាក់ឧបត្ថម្ភលើកដំបូងម្ដងគត់ស្មើនឹងបៀវត្សមូលដ្ឋានចំនួន ០៨ ខែ៖ (ខ.១.៥ = ៩៥២ ៣៨០៛x៨) | = | ៧ ៦១៩ ០៤០៛០០ |
| - ប្រាក់សោធន៍ ៧០ ភាគរយគិតតាមបៀវត្សមូលដ្ឋាន៖ | = | ៦៦៦ ៦៦៦៛០០ |
| - ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ ៦៦៦ ៦៦៦៛ ត្រូវដំឡើងឱ្យស្មើប្រាក់បៀវត្សមូលដ្ឋានអប្បបរមា ខ.១.៦ = ៩១៩ ៦២០៛ | = | ២៥២ ៩៥៤៛០០ |
| - ប្រាក់ឧបត្ថម្ភប្រពន្ធ | = | ១៥ ០០០៛០០ |
| - ប្រាក់ឧបត្ថម្ភកូនចំនួន *៣នាក់ (១០ ០០០៛/នាក់)* | = | ៣០ ០០០៛០០ |
| **ប្រាក់សោធនប្រចាំខែសរុប** | = | **៩៦៤ ៦២០៛០០** |

**ប្រការ៤ ..**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន............................ ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ប្រធានអង្គភាពពាក់ព័ន្ធ និងលោកឬលោកស្រី......................... មានភារកិច្ចអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.......................ខែ...........ឆ្នាំ...............ព.ស.២៥....

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...........ខែ.............ឆ្នាំ២០...

**រដ្ឋមន្ត្រី**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងមុខងារសាធារណៈ
- រដ្ឋបាលរាជធានី ខេត្ត......... *(ចំពោះមន្ត្រីបម្រើការងារនៅថ្នាក់រាជធានី ខេត្ត)*
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :........................................ក.ប**

| **ឧបសម្ព័ន្ធ៨** |
| --- |
| ប្រកាសមានលក្ខណៈជាបទប្បញ្ញត្តិឯកត្តភូត |

# ប្រកាស
# ស្តីពី
# ការដំឡើងឋានន្តរស័ក្តិ ថ្នាក់មន្ត្រីរាជការ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញ *(ព្រះរាជក្រឹត្យ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌនីមួយៗ)*
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងលិខិតលេខ.................... មស.គ្ររ ចុះថ្ងៃទី..... ខែ..... ឆ្នាំ...... របស់ក្រសួងមុខងារសាធារណៈ

## សម្រេច

**ប្រការ១ .-**

ដំឡើងឋានន្តរស័ក្តិ ថ្នាក់ប្រចាំឆ្នាំ និងកិត្តិយស ជូនមន្ត្រីរាជការចំនួន...............រូប នៃក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ក្របខណ្ឌមន្ត្រីបច្ចេកទេសមធ្យម ក្របខណ្ឌមន្ត្រីបច្ចេកទេសបឋម ក្របខណ្ឌសុខាភិបាលជាន់ខ្ពស់ និងសុខាភិបាលមធ្យម នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយគិតចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ ដូចមានរាយនាមខាងក្រោម:

| ល.រ | គោត្តនាម និងនាម | ភេទ | ក្របខណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ | | អត្តភាព |
|---|---|---|---|---|---|
| | | | ចាស់ | ថ្មី | |
| **ក.ក្របខណ្ឌមន្ត្រីបច្ចេកទេសឬសុខាភិបាលជាន់ខ្ពស់** | | | | | |
| ១ | .................. | ប | ក.៣.៣ | ក.៣.២ | នាយកដ្ឋាន.................. |
| ២ | .................. | ស | ក.៣.៤ | ក.៣.៣ | មន្ទីរ............................ |
| **ខ.ក្របខណ្ឌមន្ត្រីបច្ចេកទេសឬសុខាភិបាលមធ្យម** | | | | | |
| ១ | .................. | ប | ខ.៣.៣ | ខ.៣.២ | នាយកដ្ឋាន.................. |
| ២ | .................. | ស | ខ.៣.១ | ខ.២.៤ | មន្ទីរ............................ |
| **គ.ក្របខណ្ឌមន្ត្រីបច្ចេកទេសបឋម** | | | | | |
| ១ | .................. | ប | គ.៨ | គ.៧ | នាយកដ្ឋាន.................. |
| ២ | .................. | ស | គ.១០ | គ.៩ | មន្ទីរ............................ |
| **ឃ.ដំឡើងថ្នាក់ប្រចាំឆ្នាំ និងកិត្តិយស** | | | | | |
| ១ | .................. | ប | ក.៣.៣ | ក.៣.១ | នាយកដ្ឋាន.................. |
| ២ | .................. | ស | ខ.៣.១ | ខ.២.៣ | មន្ទីរ............................ |

**ប្រការ២ ..**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន ............................ ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ......................ខែ..........ឆ្នាំ..............ព.ស.២៥....

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ២០...

**រដ្ឋមន្ត្រី**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :.......................................ក.ប

**ឧបសម្ព័ន្ធ៩**
សម្រេចបង្កើតឬកែសម្រួល...................

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតឬកែសម្រួលសមាសភាពក្រុមការងារ/គណៈកម្មការ
.................................................

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញ *(ព្រះរាជក្រម ឬព្រះរាជក្រឹត្យ ដែលពាក់ព័ន្ធនឹងខ្លឹមសារប្រកាស ប្រសិនបើមាន)*
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញ *(អនុក្រឹត្យ សេចក្តីសម្រេច សារាចរ របស់រាជរដ្ឋាភិបាល ឬប្រកាស ដែលពាក់ព័ន្ធនឹងខ្លឹមសារប្រកាស ប្រសិនបើមាន)*
- *(យោងឯកសារពាក់ព័ន្ធទៅនឹងរឿង ឬអង្គភាពសាមី ប្រសិនបើមាន)*
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## សម្រេច

**ប្រការ១ ..**

ត្រូវបានបង្កើត/កែសម្រួលសមាសភាពរបស់ក្រុមការងារ/គណៈកម្មការរបស់.........................ដែលមានសមាសភាពដូចខាងក្រោម៖

- ឯកឧត្តម/លោកជំទាវ ...... (មុខតំណែង) ប្រធាន
- ឯកឧត្តម/លោកជំទាវ ...... (មុខតំណែង) អនុប្រធាន

- ឯកឧត្តម/លោកជំទាវ ...... (មុខតំណែង) សមាជិក/សមាជិកា
- លោក/លោកស្រី ...... (មុខតំណែង) សមាជិក/សមាជិកា
- លោក/លោកស្រី ...... (មុខតំណែង) សមាជិក/សមាជិកា
- លោក/លោកស្រី ...... (មុខតំណែង) សមាជិក/សមាជិកា

**ប្រការ២ .-**

ក្រុមការងារ/គណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- ........................................................................................................................
- ........................................................................................................................
- ........................................................................................................................
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាព...............ជូនប្រធានស្ថាប័នជាប្រចាំ
- អនុវត្តភារកិច្ចផ្សេងៗតាមការចាត់តាំងរបស់ប្រធានស្ថាប័ន។

**ប្រការ៣ .-**

ប្រធានក្រុមការងារ អាចអញ្ជើញអង្គភាពពាក់ព័ន្ធចូលរួមប្រជុំតាមការចាំបាច់។

សមាជិកនៃក្រុមការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ។

**ប្រការ.... .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

(ប្រការនេះមិនត្រូវចែងទេ ក្នុងករណីជាក់ស្តែងដែលមិនតម្រូវឱ្យនិរាករណ៍លិខិតបទដ្ឋានគតិយុត្តមុនៗដែលពាក់ព័ន្ធ)។

**ប្រការ.... .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន.................... (ប្រធានអង្គភាពដែលទទួលបន្ទុករៀបចំ ឬអនុវត្ត) ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ......................ខែ...........ឆ្នាំ...............ព.ស.២៥....

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...........ខែ.............ឆ្នាំ២០...

**រដ្ឋមន្ត្រី**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័ន *(ដែលពាក់ព័ន្ធ ប្រសិនបើមាន)*
- ដូចប្រការ(...) *(ប្រការចុងក្រោយនៃប្រកាស)*
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

| |
|---|
| **ឧបសម្ព័ន្ធ១០** |
| សម្រេចបង្កើតឬកែសម្រួល.................. |

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**អគ្គនាយកដ្ឋាន**..................................
**នាយកដ្ឋាន**........................................
លេខ:....................................................

## សេចក្តីសម្រេច
## ស្តីពី
## ការបែងចែកតួនាទីភារកិច្ច នីតិវិធី និងរបៀបរបបការងារ ជូនថ្នាក់ដឹកនាំ នៃអង្គភាព............................

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញ *(អនុក្រឹត្យ ឬប្រកាស ដែលពាក់ព័ន្ធនឹងអង្គភាពសាមី)*
- យោងតាមការចាំបាច់របស់របស់អង្គភាព................................។

## សម្រេច

**ប្រការ១ .. អំពីការបែងចែកភារកិច្ច**

ត្រូវបានបែងចែកភារកិច្ចជូន *ថ្នាក់ដឹកនាំនៃអង្គភាព*.................................. ដូចខាងក្រោម៖

១. ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ................ (មុខតំណែង) ជាប្រធានអង្គភាពទទួលបន្ទុកដឹកនាំការងាររួមរបស់ *(ឈ្មោះអង្គភាព)* និងមានភារកិច្ចទទួលខុសត្រូវចំពោះមុខថ្នាក់ដឹកនាំទទួលបន្ទុក

២. ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ............... (មុខតំណែង) ជួយប្រធានអង្គភាពលើការងារ *(ការិយាល័យឬផ្នែក..........)* និងអនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានអង្គភាពប្រគល់ជូន។

**ប្រការ២ .. នីតិវិធី និងរបៀបរបបការងារ**

ក. អនុប្រធាន *(អង្គភាព.......)* ឬថ្នាក់ដឹកនាំ *(ការិយាល័យឬផ្នែក.......)* ត្រូវអនុវត្តតាមការចាត់តាំងរបស់ប្រធានអង្គភាព។ ក្នុងករណីមិនអាចចូលរួមតាមការចាត់តាំងបាន ត្រូវស្នើសុំគោលការណ៍សម្រេចរបស់ប្រធានអង្គភាពជាមុនសិន មុននិងប្រគល់ភារកិច្ចជូនថ្នាក់ *(ការិយាល័យឬផ្នែក.....)* ឬមន្ត្រីជំនាញណាមួយ។ ក្រោយចប់ភារកិច្ចត្រូវរាយការណ៍ជូនប្រធានអង្គភាពដោយភ្ជាប់ជាមួយរបាយការណ៍ស្ដីពីលទ្ធផលការងារដែលទទួលបានសម្រាប់រាយការណ៍ជូនថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងតម្កល់ទុកជាឯកសារក្នុងអង្គភាព។

ខ. រាល់ឯកសារទាំងអស់នៅក្នុង *(ឈ្មោះអង្គភាព.....)* ត្រូវទទួលបន្ទុកដោយការិយាល័យឬផ្នែករដ្ឋបាល។ ការិយាល័យឬផ្នែករដ្ឋបាល ត្រូវបញ្ជូនឯកសារទៅការិយាល័យឬផ្នែកដែលពាក់ព័ន្ធដើម្បីធ្វើចំណាត់ការបន្ត និងឆ្លងយោបល់សម្រេចចុងក្រោយពីប្រធានអង្គភាព។

គ. ក្នុងករណីដែលថ្នាក់ដឹកនាំ *(អង្គភាព.....)* ទទួលបន្ទុកណាមួយ ឬថ្នាក់ដឹកនាំ *(ការិយាល័យឬផ្នែក...)* ណាមួយអវត្តមានចាប់ពី ២ថ្ងៃឡើងទៅ នោះសំណុំលិខិតទាំងឡាយត្រូវដាក់បន្តទៅថ្នាក់ដឹកនាំបន្ទាប់ ដោយកំណត់ថាអវត្តមាន ឬជាប់បេសកកម្ម រួចបញ្ជូនបន្តដើម្បីធ្វើចំណាត់ការបានទាន់ពេលវេលា។

ឃ. គ្រប់ការិយាល័យឬផ្នែកទាំងអស់របស់អង្គភាព ត្រូវរៀបចំនីតិវិធី របៀបរបបបំពេញការងារ ចរន្តលំហូរឯកសារ និងថេរវេលានៃការបញ្ជូនឯកសារឱ្យបានច្បាស់លាស់។

ង. ប្រធានអង្គភាពមានភារកិច្ចដឹកនាំប្រជុំបូកសរុបការងារប្រចាំខែ ត្រីមាស ឆមាស អឌ្ឍមាស និងប្រចាំឆ្នាំ។ ក្នុងករណីចាំបាច់ ប្រធានអង្គភាពអាចចាត់អនុប្រធានណាម្នាក់ដឹកនាំប្រជុំជំនួស។

**ប្រការ៣ ..**

